# ការសំភាសន៍របស់អ្នកមីង ហាក់ គីម សុខ

កៈ  អ្នកដែរសំភាសន៍គេមានឈ្មោះថា ជាង ស៊ីអ៊ាវ

ខៈ  អ្នកដែរអោយគេសំភាសន៍មានឈ្មោះថា ហាក់ គីម សុខ៕

<u>ការសំភាសន៍ប្រវត្តិរបស់អ្នកមីង ហាក់ គីមសុខ</u>

អ្នកមីង ហាក់ គីមសុខ មានអាយុ

អ្នកមីង ហាក់ គីមសុខ មានភេទស្រី

អ្នកមីង ហាក់គីម សុខ មានទីលំនៅបច្ចុប្បន្ន នៅភូមិ

កៈ  ចឹងជាដំបូងខ្ញុំអរគុណច្រើនមីងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់មីង ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថា BYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីអោយកូនចៅជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិឪពុកម្តាយ នឹងប្រវត្តិរបស់ដូនតា ហើយនៅពេលដែរខ្ញុំសំភាសន៍អ៊ី ហើយខ្ញុំនឹងដាក់សំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu  ចឹងហាសអ៊ី ចឹងតើអ៊ីយល់ព្រមដើម្បីអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ីដែរទេអ៊ី?

ខៈ  យល់ព្រម

កៈ  ចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍អ៊ីខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ាវ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍អ៊ីគឺនៅថ្ងៃទី 19 ខែ2 ឆ្នាំ2018 សំភាសន៍នៅ?

ខៈ  ភូមិបាល្លាំថ្មី

កៈ  ភូមិបាល្លាំថ្មី នៅឃុំ?

ខៈ  ឃុំល្អាង

កៈ  ឃុំល្អាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម ចឹងសំរាប់អ៊ីមានឈ្មោះពេញឈ្មោះអ៊ីគេដែរអ៊ី?

ខៈ  ឈ្មោះហាក់ គីមសុខ

កៈ  ចុះមានឈ្មោះហៅក្រៅទេអ៊ី?

ខៈ  អត់មានទេ

កៈ ចុះកាលពីក្មេងធ្លាប់មាននរណាហៅឈ្មោះអ៊ីអីផ្សេងទេអ៊ី?

ខៈ អត់មាន

កៈ ចឹងអត់មានទេណអ៊ី ចុះសព្វថ្ងៃនឹងអ៊ីអាយុប៉ុន្មានដែរអ៊ី?

ខៈ ខ្ញុំអាយុ49ឆ្នាំ

កៈ ចុះកើតនៅថ្ងៃខែឆ្នាំកំណើតណាអ៊ីមានចងចាំទេ?

ខៈ កើតនៅឆ្នាំ1962

កៈ ចុះថ្ងៃខែអ៊ីមានចងចាំទេ?

ខៈ កើតនៅខែមាឃ

កៈ កើតនៅខែមាឃ ប៉ុន្តែខែបារាំងអ៊ីមានដឹងថាខែអីទេ?

ខៈ អត់ដឹងទេ

កៈ ចឹងសំរាប់ឆ្នាំច័ន្ទគតិវិញតើអ៊ីឆ្នាំអីគេដែរអ៊ី លក្ខណៈឆ្នាំជូត ឆ្លូវ ខាល ថោះហាសអ៊ី?

ខៈ ខ្ញុំឆ្នាំច

កៈ អ៊ីឆ្នាំច ចុះអ៊ីកើតនៅណាដែរអ៊ី កើតនៅភូមិ ឃុំ អី?

ខៈ ខ្ញុំកើតនៅពេទ្យ

កៈ កើតនៅពេទ្យណាវិញអ៊ី?

ខៈ កើតនៅពេទ្យខេត្តកំពង់ចាមនឹង កើតនៅពេទ្យរដ្ឋ

កៈ ប៉ុន្តែដឹងតែស្រុកកំពង់ចាម ខេត្តកំពង់ចាម?

ខៈ នឹងហើយ

កៈ ចុះអ៊ីមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ី?
ខៈ មានបងប្អូនចំនួន2នាក់ ប៉ុន្តែមួយទៀតនឹងស្លាប់ដោយសារតែចូលឆ្នាំបបរ

កៈ អ្ហូ!ម៉េចចឹងអ៊ី?

ខៈ វាទៅដួសហើយពេលណុងកណ្ឌាន់វាធំហើយវាដេកនៅក្នុងអង្រឹងដល់ពេលហើយបានដាច់អង្រឹង ហើយវាក៏ធ្លាក់ចូលឆ្នាំបបរនឹងណាស់ រួចទៅវាបានឈឺស្លាប់បាត់ទៅនៅជំនាន់អាពតនឹងណាស់

កៈ ប៉ុន្តែមិញមានបងប្អូនចំនួនប៉ុន្មានដែរមីង?

ខៈ មានបងប្អូន2នាក់ ប៉ុន្តែអានោះវាស្លាប់ទៅយើងនៅតែម្នាក់ឯងរាល់ថ្ងៃនឹង

កៈ ចុះអ្នកដែរស្លាប់នឹងប្អូន រឺមួយក៏បងដែរអឺ?

ខៈ អាស្លាប់នឹងវាប្អូន

កៈ ប៉ុន្តែគាត់ស្រី រឺមួយក៏ប្រុសដែរអឺ?

ខៈ វាប្រុសតើ!

កៈ ប៉ុន្តែគាត់មានឈ្មោះអីគេដែរអឺ?

ខៈ អាណុងវាឈ្មោះគីម ស្រ៊ុន

កៈ ចឹងដូចជាគ្មានប្រវត្តិអីជាមួយគាត់ទេណាអី ដោយសារតែកាលពីគាត់ស្លាប់នឹងគាត់នៅក្មេងមែនទេ?

ខៈ នៅក្មេងនៅពេទ្យយកមកមើលនៅវត្តល្អងលើនេះ ដែរស្លាប់នឹងហោស

កៈ ប៉ុន្តែអាយុប៉ុន្មានអីពេលណុង?

ខៈ ពេលណុងអាយុប្រហែលជា5 ឆ្នាំហើយនឹង

កៈ ចឹងមានន័យថាអាយុ5ឆ្នាំហើយ ចឹងចុះធ្លាប់មានអនុស្សាវរីយ៍អីកាលពីនៅតូចៗជាមួយគាត់ដែរទេ?

ខៈ ជាមួយប្អូននឹងហោស មានតើ!

កៈ ធ្លាប់ធ្វើអីគេខ្លះជាមួយគាត់ដែរទេ?

ខៈ មានលក្ខណៈថាយើងកំព្រាឪពុកចឹងយើងបានដឹកដៃប្អូនដើរលេងចឹងទៅ ដូចថាបងប្អូនគេមិនទទួលស្គាល់ហើយគេដេញយើងចេញចឹងទៅណាស់

កៈ ចឹងហោសមីង?

ខៈ ចឹងទៅចេះតែដឹកដៃប្អូនដើរទៅមុខទៀតទៅណាស់

កៈ ប៉ុន្តែធ្លាប់មានលក្ខណៈលេងឡឹកបាយឡ រឺមួយក៏លេងបិទពួនអីជាមួយគ្នាដែរទេអឺ?

ខៈ អត់ទេដឹងតែដឹកដៃប្អូននឹងគេចពីគេចឹងទៅ

កៈ ចឹងសំរាប់គាត់បានស្លាប់បាត់ហើយណាអឺ?

ខៈ វាស្លាប់ហើយ

កៈ ចុះកាលពីក្មេងនឹងអ៊ីចូលចិត្តលេងអិគេជាមួយប្អូនរបស់អ៊ីដែរទៅ?

ខៈ អត់មានលេងអីទេដូចថា2នាក់បងប្អូននឹងនៅមើលប្អូនចុះពេលណុងម្តាយទៅធ្វើការហោស ដល់ពេលដែរបើកបបរមកមានតែរងចាំកូនទៅរកហោស ហើយគាត់បានយោអង្រឹងទៅវាបានធ្លាក់ចូលទៅក្នុងឆ្នាំបបរនឹងវាមិនទាន់ស្លាប់ភ្លាមទេ វានៅយូរដែរនឹងណាស់

កៈ បាទអ៊ី ចុះពេលណុងនៅជំនាន់ពលពតណាអ៊ី?

ខៈ នៅជំនាន់អាពតនឹងក៏គេមិនទាន់ស៊ុបដែរ ជំនាន់គេប្រមូលដំបូងហាស

កៈ បាទអ៊ីចុះកាលពីកជំនាន់ពលពតនឹងអ៊ីអាយុប៉ុន្មានដែរទៅអ៊ី?

ខៈ អ៊ីអាយុ10ឆ្នាំជាងនឹង

កៈ ចឹងមានន័យថានៅក្នុងកុមារណាអ៊ី?

ខៈ នៅកុមារហើយគេអោយទៅចិញ្ច្រាំកន្ទាំងខែតនឹង គេអោយអូសកំភ្លោកអូសយកមកចិញ្ច្រាំយកមកធ្វើជាជី គេអោយជញ្ជូនកណ្តាប់ គេអោយចាំចាប

កៈ ចុះពេលណុងគេជំលាសយើងទៅណាទៅពេលណុង?

ខៈ ពេលណុងគេមិនទាន់ជំលាសយើងទេពេលណុងនោះ យើងនៅគៀនជ្រៃយើងនៅផ្ទះយើងដដែល ប៉ុន្តែគ្រាន់តែរួមទៅបានគេជំលាសទៅនៅ ឥន្ទនេលនឹង ដល់ពេលដែរគេជំលាសពីឥន្ទនេលនឹងទៅគេមកធ្វើជាពេងវែងអិគេដូចថាតាមព្រៃស្រែអីចឹងណាស់

កៈ ប៉ុន្តែនៅណាដែរអ៊ី?

ខៈ គេធ្វើពេងអោយនៅចឹងទៅណាស់

កៈ ចុះពេលណុងនៅណាដែរអ៊ី?

ខៈ ពេលណុងមកនៅពេងវែងនៅជិតអូរតាយានៅជិតល្វលនេះ ដូចថាគេមានពេងវែងធ្វើអោយនឹងចឹងសំរាប់អ្នកធ្វើស្រែដើម្បីអើយគេស្នាក់នៅចឹងទៅណាស់

កៈ ប៉ុន្តែអ៊ីពេលណុងគេអោយធ្វើអីគេដែរទៅអ៊ី?

ខៈ នៅពេងណុងគេអោយវែកកណ្តាប់វែកអីចឹងទៅ វែកមុនដំបូងបានមួយខាង2កណ្តាប់ ដល់ពេលយូរៗទៅមួយខាងមួយកណ្តាប់ ដល់ពេលយូរៗទៀតទៅសឹងតែអោបកណ្តាប់មិនរួចផងនឹង
យើងដួលនៅណុងតែម្តង

កៈ ម៉េចចឹងអ៊ីអត់អហារមែនអ៊ី?

ខ៖ ដូចថាយើងឃ្លានបាយយើងនៅស្ទើរហាស

ក៖ យើងនៅក្មេងៗណាអ៊ី?

ខ៖ នឹងហើយពេលឃ្លានបាយទៅដេកនៅស្រែនឹងទៅដល់ពេលដែរបងប្អូនគេឃើញទៅគេបានលើបី យកទៅរោងអីចឹងទៅណាស់

ក៖ ប៉ុន្តែរបបអាហារអីគេអោយយ៉ាងម៉េចទៅវិញទៅអ៊ី?

ខ៖ អាហារស៊ីមិនដែរឆ្អែតទេនឹង នៅតូចចឹងប៉ុន្តែនៅជីកដំឡូងនៅក្នុងព្រៃចឹងទៅ ហើយស៊ីប៉ះក្លូចអីចឹង ទៅពុលទៅ

ក៖ ប៉ុន្តែពុលលក្ខណះថាអត់អីណាហីអ៊ី?

ខ៖ អត់អីទេបានគេជួយដែរ

ក៖ ចុះរហូតមកដល់ពេលពតនឹងគ្រួសាររបស់អ៊ីនឹងធ្វើអីគេដែរទៅ?

ខ៖ ដល់ពេលពលពតនឹងគេអោយអ៊ីបកពោត បកពោតនឹងបកចេកគេស្ងោររួចយើងជាអ្នកទៅបកចឹង ទៅចាស់ៗគេជាអ្នកឈូសនៅគៀនជ្រៃក្រៅនឹងណាស់

ក៖ ប៉ុន្តែគ្រួសាររបស់អ៊ីធ្វើអីទៅពេលណុង?

ខ៖ ឪពុកម្តាយនឹងមានតែម្តាយទេ ឪពុកបានស្លាប់បាត់ហើយ ម្តាយនឹងគេយកគាត់ទៅទំនប់ត្រួយចេក

ក៖ ប៉ុន្តែមិនអោយនៅជាមួយគ្នាណាហីអ៊ី?

ខ៖ អត់ទេ

ក៖ អូ៎!រហូតទាល់តែដាច់ពលពតណអ៊ី?

ខ៖ ទាល់តែដាច់អាពតនឹងបានបានជួបគ្នា

ក៖ ប៉ុន្តែនៅពេលដែរពលពតនឹងអ៊ីមានការលំបាកអីផ្សេងទៀតទេអ៊ី?

ខ៖ មានការលំបាកហើយពីព្រោះតែយើងមានឪពុកចុងយើងមិនសូវជាចូលចិត្តគាត់ចឹងយើងក៏រត់ទៅ នៅជាមួយមីង មា នឹងឪពុកធំខាងគៀនជ្រៃនឹងចឹងហាស

ក៖ ចឹងមានន័យថាម្តាយរបស់អ៊ីនឹងគាត់យកប្តីមួយទៀត?

ខ៖ គាត់បានយកប្តីមួយទៀត

ក៖ ពេលដែរដាច់ពលពតនឹងហីអ៊ី?

ខ៖  នឹងហើយ

ក៖  ចឹងរហូតទាល់តែអីមានគ្រួសារណាអ៊ី?

ខ៖  ទាល់តែមានគ្រួសារនឹងជាមួយគាត់ក៏ដូចជានៅតែមិនស្និទ្ធិស្នាលដែរម្ដាយនឹងកូនដែររត់ទៅនៅជាមួយម្ដាយធំឪពុកធំនឹងណាស់

ក៖  ចឹងហោសអ៊ី?

ខ៖  ដល់ពេលដែរទៅនៅជាមួយគេចឹងទៅរែកទឹក រែកអូសហើយស៊ីបាយគេចឹង

ក៖  ចុះអ៊ីគិតថានៅពេលដែរអ៊ីមានគ្រួសារអ៊ីគិតថាមានការលំបាកអីផ្សេងទៀតអត់អ៊ី?

ខ៖  លំបាកដែរនឹងមានបេះស្លឹកបាស បេះត្រួយថ្នឹង ត្រួយអីចឹងបេះបន្លែអីយកទៅលក់ចឹង លក្ខណះមានដក់ខ្ទារឈូកងីចឹងយកទៅលក់ ចូកកំពិស បេះកញ្ចាប់ ប្រវត្តិទាំងអស់និយាយការពិតទាំងអស់នឹងអត់មានកុហកទេ

ក៖  ចុះអ៊ីគិតថាពេលដែរមានកូននឹងអ៊ីគិតថាមានការលំបាកអីទេអ៊ី?

ខ៖  មានកូននឹងក៏មានការលំបាកពីព្រោះយើងនឹងទីទាល់ក្រហាស យើងចេះតែប្រឹងរកទៅតិចៗទៅជូនកាលទៅបានមួយពេលទៅល្ងាច រកទៀតទៅពេលដែរយើងដាច់នឹង

ក៖  ប៉ុន្តែឥឡូវនឹងអ៊ីធូរហើយមែនទេអ៊ី?

ខ៖  ដល់ពេលឥឡូវនឹងបានកូនធំទៅវាចេះជួយរកនឹង

ក៖  ចឹងមានន័យថាវាធូរជាងពីមុនហើយណាអ៊ី?

ខ៖  វាធូរជាងមុននឹង

ក៖  ចុះអ៊ីគិតថាមានឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរអ៊ី?

ខ៖  ឆ្លងកាត់ការលំបាកពេលដែរយើងមានកូននឹងហោស?

ក៖  ទាំងពេលពលពតទាំងពេលដែរយើងមានគ្រួសារនឹងពេលដែរយើងមានកូនអីចឹងទៅណាស់អ៊ី?

ខ៖  ពេលដែរយើងមានកូននឹងយើងវាលំបាកដែរប៉ុន្តែគ្រាន់តែយើងរកខ្លួនឯង យើងចាប់តាំងខ្លួនឯងនឹងយើងគិតខ្លួនឯងវាមិនដូចគេប្រើយើងអត់បាយអត់ទឹកចឹងទៅណាស់

ក៖  ចឹងហោសអ៊ីបាទ?

ខ៖  វាខុសគ្នាសូម្បីតែដេកនឹងគ្មានទាំងភួយដណ្ដប់ផងនឹងមានតែខោអាវនឹង ខោអាវនឹងគ្មានស្លៀកផងនឹងគេអោយមួយចង្កេះ ចុះកុមារគេអោយមនុស្សធំមក ហើយយកទៅបោកសុទ្ធតែឈាម

កៈ ស្លៀកមិនត្រូវហោសអ៊ី?

ខៈ ស្លៀកមិនត្រូវទេប៉ុន្តែចេះតែស្លៀកទៅណាស់ ចុះរងាហោសចឹងហាស់

កៈ លក្ខណៈយកមួយនឹងធ្វើជាភួយហោសអ៊ី?

ខៈ នឹងហើយយកមកស្លៀក យកមកពាក់នឹងធំយ៉ាងម៉េចក៏ដោយអោយតែជិតនឹងណាស់

កៈ អូ៎!បាទអ៊ី ចុះឪពុករបស់អ៊ីនឹងគាត់មានឈ្មោះអីគេដែរអ៊ី?

ខៈ គាត់មានឈ្មោះខែម ហាក់

កៈ ចុះគាត់កើតនៅថ្ងៃខែឆ្នាំណាអ៊ីមានចងចាំទេ?

ខៈ គាត់អាយុច្រើនហើយចង់ហុកសិប ចង់ចិតហើយពីព្រោះបងម៉ែ12ឆ្នាំណោះនឹង

កៈ ប៉ុន្តែគាត់កើតនៅណាដែរអ៊ីមានដឹងទេ?

ខៈ គាត់កើតនៅគៀជ្រៃស្រុកកំណើតរបស់គាត់នៅគៀនជ្រៃនឹង

កៈ ចុះម្ដាយរបស់អ៊ីនឹងមានឈ្មោះអីគេដែរអ៊ី?

ខៈ មានឈ្មោះឈាង ភេន

កៈ ចុះគាត់កើតនៅណាដែរអ៊ី?

ខៈ គាត់កើតនៅភូមិពង្រ

កៈ ភូមិពង្រនឹងនៅណាដែរអ៊ី?

ខៈ គឺនៅទួលប្រសាទនឹង ឃុំជ្រាន

កៈ អូ៎!នៅជ្រានយើងនឹងហោសអ៊ី ចុះឪពុករបស់អ៊ីនឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ី?

ខៈ ពីដើមមកគាត់ធ្វផ្ទុះ គាត់រកស៊ីខាងធ្វើជាផ្ទុះនឹង

កៈ នឹងកាលពីគាត់នៅភរស់ហោសអ៊ី?

ខៈ នឹងហើយគាត់ដាក់ត្រី

កៈ ប៉ុន្តែគាត់ស្លូត រឺមួយក៏កាចដែរអ៊ី?

ខៈ គាត់ស្លូតទេនឹង

កៈ ចុះម្ដាយរបស់អ៊ីវិញគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរអ៊ី?

ខ៖  គាត់លក់ត្រីដែរអីនឹង

ក៖  ចុះគាត់កាចរឺមួយក៏ស្លូតដែរអី?

ខ៖  គាត់មិនកាច គាត់មិនស្លូតទេនឹងគាត់ធម្មតានឹង

ក៖  ចុះកាលពីអីនៅជាមួយឪពុកម្ដាយរបស់អី អីមិនទាន់មានគ្រួសារហោសតើអីធ្លាប់មានប្រវត្តិអីជាមួយគ្នាដែរទេអី?

ខ៖  ជាមួយម្ដាយហោស?

ក៖  ជាមួយទាំងម្ដាយនឹងជាមួយទាំងឪពុកហាស?

ខ៖  និយាយអោយត្រង់ទៅទាំងម្ដាយនឹងទាំងឪពុកនឹងគាត់ដូចជាមិនស្និទ្ធិស្នាលជាមួយនឹងយើងទេនឹងគាត់គិតតែកូនគាត់ក្រោយអីចឹងទៅណាស់ គាត់ដូចថាមិនសូវគិតទេ ធ្វើអីមួយក៏មិនពេញចិត្តគាត់ដែរនឹងចឹងហាស

ក៖  អ៎ូ!លក្ខណៈថាគាត់ចេះតែជំទាស់រហូតអីចឹងហោសអី?

ខ៖  នឹងហើយចឹងសូម្បីតែសំដីនឹងក៏មិនសូវស្និទ្ធិស្នាលដូចម៉ែឪអស់គេដែរនឹង

ក៖  ចុះឪពុករបស់អីនឹងកាលពីគាត់នៅរស់នឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅអីដែរទេអី?

ខ៖  គាត់នៅរស់និយាយទៅគាត់នៅក្មេងចឹងម៉ែឪគាត់គ្រាន់បើហើយមានកូនតែគាត់មួយនឹង ប៉ុន្តែគាត់ចេះរកស៊ីគាត់ឆ្លាតគាត់រៀនបានច្រើនអីចឹងទៅណាស់

ក៖  នឹងឪពុកហោសអី?

ខ៖  ឪពុកមិញនឹងឈ្មោះខែម ហាក់

ក៖  ប៉ុន្តែឪពុកនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅអីដែរទេ?

ខ៖  អត់បានប្រាប់អីផងនឹងពីព្រោះអីនៅតូចចឹងហាស

ក៖  ដល់ពេលចឹងគាត់ស្លាប់មុនចឹងទៅ?

ខ៖  គាត់យកគាត់ទៅសំលាប់ដែរនឹង

ក៖  អ៎ូ!ចឹងមានន័យថាឪពុករបស់អីនឹងស្លាប់នៅជំនាន់ពលពតនឹង?

ខ៖  នឹងហើយគាត់សំលាប់មុនអាពត

កៈ កើតអីបានគេយកទៅ?

ខៈ គេចោទគាត់ថាគាត់មានកាំភ្លើង មានគ្រាប់បែកអីចឹងទៅណាស់

កៈ ប៉ុន្តែកាលណុងគាត់ធ្វើអីគេបានគេយកគាត់ទៅ?

ខៈ គាត់ធ្វើតែផ្ទះចាប់ត្រីនឹងគាត់មានកាំភ្លើង មានគ្រាប់បែកមកពីណា

កៈ គាត់ធ្វើផ្ទះនៅគៀនជ្រៃនឹងហោសអី?

ខៈ នឹងហើយរួចទៅគេចោទគាត់ ហើយគេក៏ចាប់គាត់យកទៅនឹង

កៈ ចុះអីមានចងចាំយាយតាខាងឪពុកហាស ពួកគាត់នឹងឈ្មោះអីគេដែរ?

ខៈ យាយឈ្មោះយាយ ដួប ចំណែកតាវិញឈ្មោះតាខែម

កៈ នឹងខាងឪពុក?

ខៈ ខាងឪពុកនឹងខាងម្តាយបើឪពុករបស់គាត់នឹងមិនស្គាល់ទេនឹង

កៈ ចុះគាត់កើតនៅណាអីដឹងទេ?

ខៈ គាត់កើតនៅគៀនជ្រៃនឹង

កៈ កើតនៅគៀនជ្រៃទាំងអស់គ្នានឹងហោសអី?

ខៈ កើតនៅពេទ្យប៉ុន្តែស្រុកកំណើតនៅពេទ្យទេ

កៈ ចុះអីនៅនឹងយូរនៅអី?

ខៈ នៅនឹងគិតទៅប្រហែលជា20ឆ្នាំជាងហើយនឹងថាជាង30ឆ្នាំហើយដែរនៅនឹង

កៈ ពីមុនដែរអីនៅនឹងអីនៅណាដែរ?

ខៈ អីនៅគៀនជ្រៃ

កៈ អីគៀនជ្រៃរហូតហោសអី?

ខៈ នៅគៀនជ្រៃរហូតនឹង

កៈ ទើបតែមកប្តូរនៅនឹងឆ្នាំណាអីមានដឹងទេ?

ខៈ មិនដឹងឆ្នាំណាទេមើលអាជាអាយុ26ឆ្នាំហើយនឹង តាំងមកនៅស្រុកនឹងអស់30ឆ្នាំហើយនឹងនៅឆ្នាំថ្មីនឹងហោស

កៈ ពីមុនកូនអ៊ីកើតទៀតហោសអ៊ី?

ខៈ មកយូរហើយបានមានកូនមិនមែនមានភ្លាមណាមកនៅជិត3ឆ្នាំហោសបានមានកូននឹង

កៈ ចុះអ៊ីមានកូនចៅណា រឺមួយក៏បងប្អូនណាដែរទៅរស់នៅក្រៅប្រទេសទេអ៊ី?

ខៈ អត់មានផងនឹង

កៈ ចឹងនៅថៃ វៀតណាមអីក៏អត់មានដែរ?

ខៈ អត់មានទេមានតែម្ដាយមីងដែរបាត់ជំនាន់អាពត2នាក់មិនដឹងថាគាត់រស់រឺមួយក៏គាត់ស្លាប់ផងនឹង

កៈ ចឹងអ៊ីមិនដឹងថាគាត់នៅណាទេណាអ៊ី?

ខៈ ចា៎!នឹងហើយ

កៈ ចុះស្វាមីរបស់អ៊ីនឹងមានឈ្មោះអីគេដែរអ៊ី?

ខៈ គាត់ឈ្មោះស្រេង ផល

កៈ ចុះអ៊ីមានចងចាំថ្ងៃខែដែរអ៊ីរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នឹងនៅថ្ងៃខែឆ្នាំណាដែរទេ?

ខៈ រៀបនៅឆ្នាំមមែ ការនឹងនៅឆ្នាំមមែនឹង

កៈ ឆ្នាំមមែមានច្រើនណាស់ខ្ញុំមិនដឹងថាឆ្នាំអីគេផងនឹង?

ខៈ ឆ្នាំមមែននឹងវាអាយុ27ឆ្នាំហើយ

កៈ អ៊ីរៀបការហើយដូចជាអ៊ីមានកូនភ្លាម រឺមួយក៏នៅទេអ៊ី?

ខៈ អត់ទាន់មានភ្លាមផងនឹង

កៈ នៅប៉ុន្មានឆ្នាំបានអ៊ីមានកូន?

ខៈ នៅអស់3ឆ្នាំហោសមិនដឹងថាការឆ្នាំណាទេភ្លេចដែរនឹង

កៈ អស់រយះពេល3ឆ្នាំហើយកូនរបស់អ៊ី26ឆ្នាំ ចឹងមានន័យថាអ៊ីការអស់29ឆ្នាំហើយនឹង?

ខៈ នឹងហោស អស់29ឆ្នាំហើយ

កៈ ចឹងពេលដែរអ៊ីការនឹងគិតថាឪពុកម្ដាយជាអ្នករៀបអោយរឺមួយក៏អ៊ីជាអ្នករៀបចំអោយដែរអ៊ី?

ខៈ អត់ទេគេចូលត្រឹមត្រូវហាស ម៉ែឪរៀបអោយត្រឹមត្រូវនឹង

កៈ អូ៎!បាទអ៊ី ប៉ុន្តែមានជាជំនូនអត់អ៊ី?

ខ៖  កាលណុងគេដណ្ដឹងឆាប់អត់មានភ្ជាប់ពាក្យអីទេនឹង គេរើសថ្ងៃការតែម្ដងនឹង

ក៖  ប៉ុន្តែមានជាជំនូនថ្លៃទឹកដោះអីទេអី?

ខ៖  មានតើ!

ក៖  មានប៉ុន្តែដូចជាប៉ុន្មានដែរអី?

ខ៖  កាលណុងយកតុគេបាន18តុនឹង នឹងនិយាយអោយត្រង់នឹងណាស់

ក៖  ចុះអីអាចប្រាប់ខ្ញុំបានទេថាអីស្គាល់ប្ដីរបស់អីនៅពេលណា ហើយហេតុអីបានជាអីស្រលាញ់គ្នាអីចឹងហាសអី?

ខ៖  និយាយរួមទៅអីទៅជួបគ្នាពេលណុងទៅការគេ បើថាអោយអីស្រលាញ់នឹងអីមិនស្រលាញ់ទេនឹងនិយាយត្រង់ក្នុងណុងប៉ុន្តែតាមម៉ែឪនឹង និយាយតាមការពិតតែម្ដងនឹងតាមម៉ែឪនឹង

ក៖  អត់ស្រលាញ់ចឹងសំបែកតែម្ដងនឹង?

ខ៖  នឹងហើយតាមម៉ែឪតើ!នឹង

ក៖  ចុះពូគាត់ស្រលាញ់អីប៉ុន្មានឆ្នាំបានគាត់ចូលស្ដីដណ្ដឹងអីដែរទៅ?

ខ៖  អត់ដឹងទេទាល់តែសួរគេទៅនឹង

ក៖  ចឹងពេលដែរខ្ញុំសំភាសន៍គាត់បានខ្ញុំសួរគាត់នឹង?

ខ៖  សួរគេទៅយើងមិនដឹងដែរនឹង

ក៖  ចុះអីមានចេះអាន រឺមួយក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរអី?

ខ៖  ខ្ញុំរៀនបានតែថ្នាក់ទី2នឹង រួចរៀនទៅដូចថាត្រីត្រូវរនោចចឹង និយាយរួមរៀនបានតែរនោចទេសំរាប់ខ្មើតមិនបានរៀនទេនឹង ក្នុងមួយខែនឹងរៀនបាន5ថ្ងៃនឹង

ក៖  ប៉ុន្តែរៀនបានថ្នាក់ទីប៉ុន្មានដែរអី?

ខ៖  រៀនបានថ្នាកទី2នឹង

ក៖  ចឹងមានន័យថារៀនបានថ្នាក់ទី2នឹងទៅក៏ឈប់រៀនទៅណាអី?

ខ៖  ឈប់រៀនពីព្រោះមើលប្អូនម៉ែយកប្ដីក្រោយនឹងគេមានកូនចឹងមើលតាំងពីកូន2ខែនឹង យើងក្រដៀតដើរអោយគេសំបៅផងអីផងនឹង

ក៖  ចឹងការពីអីរៀននឹងអីរៀននៅសាលាណាដែរទៅអី?

ខ៖  សាលាគៀនជ្រៃនឹង សាលាដើមអំពិលកាលសាលាគេធ្វើមន្ទីរពេទ្យកាលពីជំនាន់អាពតហោស

ក៖  ប៉ុន្តែឈ្មោះសាលានឹងមានឈ្មោះអីគេដែរអ៊ី?

ខ៖  ឈ្មោះសាលាអំពិលត្រចមនឹង

ក៖  ឈ្មោះសាលាអំពិលតាចម?

ខ៖  នឹងហើយគេដាក់ឈ្មោះសាលាចឹងកាលពីមុននឹង

ក៖  ចុះអ៊ីធ្លាប់មានមិត្តភក្តិដែរធំធាត់មកជាមួយគ្នាដែរទេអ៊ី កាលពីក្មេងហាសអ៊ី?

ខ៖  ដូចជាគ្មានមិត្តភក្តិណាទេមានតែជីដូនមួយៗឯងនឹង

ក៖  អាចប្រាប់ឈ្មោះមួយចំនួនបានទេអ៊ី?

ខ៖  ជីដូនមួយនឹងមានដូចជាមីជា មីធី ចែអយ មីចាន់បណ្ដើរគ្នាទៅរៀនចឹងថាអោយមានមិត្តភក្តិអោយដូចឥឡូវនឹងគ្មានទេនឹង

ក៖  ប៉ុន្តែអ៊ីធ្លាប់មានប្រវត្តអនុស្សាវរីយ៍អីគេជាមួយគាត់ខ្លះដែរទៅអ៊ី?

ខ៖  និយាយទៅមានប្រវត្តិអនុស្សាវរីយ៍នឹងមានតែយើងទៅនៅផ្ទះគេនឹង យើងចេះតែប្រឹងធ្វើការអោយគេចឹងទៅ ចុះយើងទៅស្នាក់អាស្រ័យជាមួយគេ

ក៖  ចុះធ្លាប់មានដើរលេងជាមួយគ្នាអី?

ខ៖  អត់មានដែរដើរលេងអីទេ

ក៖  ទៅស្រែជាមួយគ្នាអីមានទេ?

ខ៖  អត់មានទេកើតទុករហូតនឹង ដូចថាអត់មានចិត្តសប្បាយអីនឹងគេហាសទុករហូតនឹងទុកម្នាក់ឯងនឹងនឹងចឹង

ក៖  បាទអ៊ី ចុះអ៊ីមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេអ៊ី?

ខ៖  អត់ចេះទេ

ក៖  អង់គ្លេសអីក៏អត់ដែរ?

ខ៖  គ្មានចេះទេនឹងអត់ចេះទាំងអស់នឹង

ក៖  ចុះអ៊ីធ្លាប់ធ្វើស្រែចំការអត់អ៊ី?

ខ៖  ធ្លាប់ដែរនឹង

កៈ អ៊ីអីគេខ្លះនៅស្រែចំការនឹងអ៊ី?

ខៈ ស្រែចំការនឹងធ្វើស្រែធ្វើចំការជូនកាលចឹងទៅដាំអំពៅចឹងទៅ
ជូនកាលទៅដាំបិះគុកនឹងការនៅជាមួយម៉ែនៅល្វលនឹង

កៈ ចុះអ៊ីធ្លាប់បើកអាជីវកម្មលក់ដូរអីអត់អ៊ី?

ខៈ ធ្លាប់លក់ត្រី លក់អីនៅផ្សារពីមុននឹង

កៈ ចុះអ៊ីមានធ្លាប់ចិញ្ចឹមមាន់ ចិញ្ចឹមទា ចិញ្ចឹមគោ ចិញ្ចឹមក្របីអីទេអ៊ី?

ខៈ គោធ្លាប់ចិញ្ចឹម ជ្រូកធ្លាប់ចិញ្ចឹមដែរ មាន់ធ្លាប់ចិញ្ចឹមកូនចិញ្ចឹមអីតិចតួចចឹងដែរនឹង

កៈ ចុះអ៊ីគិតថាអ៊ីធ្លាប់ធ្វើការងារអីគេខ្លះតាំងពីក្មេងរហូតមកដល់ពេលនេះហាស ពីក្មេងធ្លាប់ធ្វើអីគេខ្លះរហូតដល់ឥឡូវនឹងធ្លាប់ធ្វើអីគេខ្លះដែរចឹងហាសអ៊ី?

ខៈ និយាយទៅនឹងយើងជាកសិករយើងគ្មានដីអីច្រើននឹងគេទេ ចឹងខែព្រៃត្រពាំងយើងដុះយើងទៅរកត្រពាំង យើងទៅអ៊ុំទូករកខ្ចាវឈ្មូក ប្ដីឡើងត្នោតអ៊ុំទូកទៅកាប់អូស កាប់អីយកទៅដុកស្កអីចឹងទៅណាស់វាចឹងនឹង

កៈ ចុះអ៊ីគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះអ៊ីគិតថាជីវិតរបស់អ៊ីនឹងមានការផ្លាស់ប្ដូរអីគេខ្លះដែរទៅអ៊ីមានទេ?

ខៈ អត់មានផ្លាស់ប្ដូរទេដូចថានៅតែពិបាកដដែរនឹង ពីព្រោះថាយើងអត់ទៅនឹងយើងមិនមានអីទេនឹង

ទាល់តែយើងប្រឹងស្អីក៏ដោយនឹង

កៈ ចុះទាំងជីវភាព ទាំងសុខភាពអីនឹង?

ខៈ ទាំងជិវភាព ទាំងសុខភាពអីនឹងទាំងអស់តែម្ដងនឹង

កៈ ប៉ុន្តែគ្រាន់តែថាពីក្មេងនឹងវារៀងពិបាកជាងឥឡូវនឹងហីអ៊ី ប៉ុន្តែរៀងធូរជាងមុនហីអ៊ី?

ខៈ ធូរមែនគ្រាន់តែគេមើលមកបានថាធូរ ប៉ុន្តែនៅក្នុងចិត្តរបស់យើងនឹងនៅតែពិបាលដដែរនឹង

កៈ ម៉េចចឹងអ៊ី?

ខៈ នៅខ្វះសព្វខ្វះគ្រប់នឹងវាមិនគ្រប់ដូចគេទៅណាស់

កៈ បាទចុះអ៊ីចូលចិត្តពិសារម្ហូបអីគេដែរអ៊ី?

ខៈ ស្អីក៏ហូបដែរអោយតែមាន

កៈ ប៉ុន្តែលក្ខណៈថាដែរអ៊ីចូលចិត្តស្លម្ល ស្ងោរ ឆា ការី ចៀនអីចឹង

ខៈ និយាយទៅបើមានលទ្ធភាពចូលចិត្តវិញនឹងចូលចិត្តទាំងអស់នឹងប៉ុន្តែ សំខាន់ជាងគេនឹងស្លម្ល ស្លប្រហើរត្រីល្អិតៗនឹងរាល់ថ្ងៃហើយ

កៈ ដែរអ៊ីចូលចិត្តនឹងហោសអ៊ី?

ខៈ ដែរអ៊ីចូលចិត្តនឹង

កៈ ចុះល្បែងប្រជាប្រិយ៍អីដែរអ៊ីចូលចិត្តលេងតាំងពីក្មេងរហូតមកដល់ពេលនេះហាស

ខៈ និយាយទៅមិនចូលចិត្តការសប្បាយទាំងអស់នឹងពីព្រោះនឹងនៅគិតច្រើននៅឡើយនឹង

កៈ ចុះកាលពីក្មេងនឹងអ៊ីមានចូលចិត្តលេងបោះអង្គុញ ចោលឈូង លាក់កន្សែងអីនៅតាមវត្តដែរទេអ៊ី?

ខៈ អត់មានទេនឹងរាល់ថ្ងៃនេះបើនៅក្នុងចិត្តដែរចូលចិត្តនឹង សុំសិល្ប៍ស្តាប់លោកទេស ហើយនឹងបុណ្យទានអីចឹង

កៈ អ្ហូ!បាទអ៊ី?

ខៈ មានតែប៉ុណ្ណឹងខ្ញុំនឹង

កៈ ចុះអ៊ីមានចេះច្រៀងទេ?

ខៈ អត់ចេះទេនឹង

កៈ ប៉ុន្តែអ៊ីចូលចិត្តស្តាប់បទចំរៀងទេអ៊ី?

ខៈ អត់ចូលចិត្តស្តាប់ចំរៀងទេ

កៈ ប៉ុន្តែអ៊ីចូលចិត្តស្តាប់អីគេដែរទៅចឹង?

ខៈ ចូលចិត្តស្តាប់លោកទេសហើយនឹងស្មូតនឹង

កៈ អ្ហូ!ចឹងហោសអ៊ី?

ខៈ ហើយនឹងចូលចិត្តស្តាប់ភ្លេងសៀមនឹង

កៈ ចុះបើសិនជាល្ខោន រឺក៏យីកេអីនឹងអ៊ីចូលចិត្តមើលចូលចិត្តស្តាប់ដែរទេអ៊ី?

ខៈ អត់ទេ

កៈ ចឹងអត់ដែរហោសអ៊ី ចុះមាននរណាគេនៅក្នុងផ្ទះរបស់អ៊ីនឹងចេះលេងឧបករណ៍ភ្លេងដែរទេអ៊ី?

ខ៖  អត់មាននរណាគេចេះផងនឹង

ក៖  បងប្អូនក៏អត់ចេះដែរ?

ខ៖  អត់មានទេ

ក៖  ចុះផ្ទះរបស់អ៊ីមានលក្ខណៈបែបណាដែរអ៊ីតាំងពីក្មេងរហូតមកដល់ពេលនេះហាស លក្ខណៈថាពីក្មេងនឹងផ្ទះយ៉ាងម៉េច ហើយឥឡូវនឹងផ្ទះយ៉ាងម៉េចចឹងហាសអ៊ី?

ខ៖  ពីក្មេងមកនឹងផ្ទះតូចទេជំនាន់ណុងហោស យើងធ្វើដូចជាខ្ទមស្រែអីចឹង ហើយយើងយកសំបកអាកាមកនឹងយកសំបកវានឹងមកធ្វើជាជញ្ជាំងនឹង ហើយនឹងក្រាលមកធ្វើជារនាបនឹង

ក៖  បាទអ៊ីបាទ?

ខ៖  នៅវាពិបាកដែរឥឡូវនឹងវាគ្រាន់ជាងមុនគ្រាន់តែថាយើងបានផ្ទះបានអីនៅចឹងហាស

ក៖  អូ៎!ចឹងហោសអ៊ី?

ខ៖  គ្រាន់តែថាយើងមានតែសំបកផ្ទះនឹង វាមានការខ្វះជីវភាពច្រើនដែរវាមិនបាននឹងសំបូរសប្បាយនឹងធូរធានឹងការត្រេកអរនឹងការសប្បាយដូចគេកើតទេនឹង

ក៖  អូ៎!ចឹងហោសអ៊ី?

ខ៖  ពីព្រោះតែយើងអត់ចឹងយើងគិតច្រើនដែរនឹង

ក៖  ចុះអ៊ីគិតថាផ្ទះរបស់អ៊ីនឹងនរណាគេជាអ្នកសាងសងដែរអ៊ី?

ខ៖  ផ្ទះនឹងហោស ផ្ទះនឹងប្រឹងរកស៊ីជាមួយប្ដីប្រពន្ធនឹងសំរាប់ធ្វើនឹង

ក៖  ប៉ុន្តែលក្ខណៈថាជួលគេរឺមួយក៏សាងសងខ្លួនឯងដែរអ៊ី?

ខ៖  ជួលគេនឹង

ក៖  ប៉ុន្តែប្តីរបស់អ៊ីនឹងគាត់ចេះសាងសងផ្ទះដែរទេអ៊ី?

ខ៖  អត់ចេះទេបានធ្វើកូនជាងគេនឹង

ក៖  ចុះអ៊ីមានដឹងថាផ្ទះនឹងនៅពេលដែរធ្វើនឹងគេមានប្រើឧបករណ៍អីគេខ្លះសំរាប់ធ្វើដែរទេអ៊ី?

ខ៖  ធ្វើផ្ទះនឹងហោសត្រូវការកាំបិត ពូថៅ ពន្លាក់ ដែកឈូស អីចឹងទៅណាស់

ក៖  បាទអ៊ី ចុះអ៊ីគិតថាជំនាញអីដែរអ៊ីគិតថាអ៊ីចេះស្ទាតជំនាញដែរអ៊ី?

ខ៖  ជំនាញដៃរខ្ញុំចេះស្ទាត់នឹងគឺលក់ដូរនឹង ប៉ុន្តែវាហួសពេលហើយនឹងពីព្រោះនឹងយើងសុំសិល្ប៍ហើយនឹងណាស់ ចឹងទៅលក់វាមិនកើតនឹង

ក៖  ចុះឪពុកម្តាយនឹងគាត់មានធ្លាប់បង្រៀនពីជំនាញអីទៅអ៊ីដែរទេ លក្ខណះដូចថាវេញវល្លិ៍ កូរស្ករ?

ខ៖  និយាយទៅនឹងគាត់មិនសូវជាបង្រៀនពីជំនាញអីទៅដល់យើងទេនឹង យើងដូចថាគិតខ្លួនឯងនឹងប្រាជ្ញានឹងណាស់

ក៖  ប៉ុន្តែលក្ខណហាធ្វើម្ហូបអីនឹងគាត់បង្រៀនដែរណអ៊ី?
ខ៖  គាត់បង្រៀននឹង

ក៖  មិញនឹងខ្ញុំបានសួរពីការលំបាករបស់អ៊ីមីញហើយអស់ហើយណអ៊ី?

ខ៖  ហើយអស់ហើយនឹង

ក៖  ចឹងចុះពេលដៃរសប្បាយវិញ អ៊ីគិតថាពេលណាដៃរអ៊ីគិតថាជាពេលដៃរសប្បាយនៅក្នុងឆាកជីវិតរបស់អ៊ីដៃរចឹងហាស?

ខ៖  នៅក្នុងឆាកជីវិតនឹងសប្បាយអោយតែគេថាធ្វើបុណ្យអីចឹងទៅ ទៅវត្តយើងនឹងមានមួយស្រះទៅទោះបីបច្ច័យយើងមានតិចតួចនឹងក៏យើងនៅតែញញឹមកើតដៃរនឹង

ក៖  អ្ហ៎!ចឹងហោសអ៊ី ចឹងមានន័យថាពេលដៃរអ៊ីសប្បាយនឹងជាពេលដៃរអ៊ីបានទៅធ្វើបុណ្យនឹង?

ខ៖  នឹងហើយធ្វើបុណ្យ

ក៖  ចុះអ៊ីគិតថាកាលពីនៅក្មេងនឹងអ៊ីថ្លាប់មានក្តីស្រម៉ៃថាពេលដៃរអ៊ីធំឡើងនឹងអ៊ីចង់ធ្វើអីគេដៃរទេអ៊ី?

ខ៖  និយាយទៅអត់ចង់ស្រម៉ៃអីទេ ចង់សុំថាអោយតែបានដូចថាម្ហូបចុកគ្រប់គ្រាន់អីចឹងទៅ

ក៖  អត់ទេកាលពីអ៊ីនៅតូចហាស កាលនៅរៀនហាស?

ខ៖  កាលពីនៅតូចនឹងចង់ធ្វើជាគ្រូ ចង់រៀនបានចង់ធ្វើជាគ្រូអីចឹងទៅណាស់

ក៖  ម៉េចបានចង់ធ្វើជាគ្រូវិញអ៊ី?

ខ៖  ចង់ធ្វើគ្រូដូចថាចង់ធ្វើជាគ្រូអីចឹងបាន បានបង្រៀនកូនចៅជំនាន់ក្រោយនឹងតទៅទៀតនឹង

ក៖  អ្ហ៎!លក្ខណះចង់ជួយពួកគាត់ហោសអ៊ី?

ខ៖  ប៉ុន្តែប្រលងនឹងមិនបានសំរេចទេពីព្រោះថាម៉ែឪអោយនៅមើលប្អូនអីចឹងទៅណាស់ ចឹងទៅយើងមិនបានរៀនទេនឹង

ក៖  អ្ហ៎!លក្ខណះថាអោយយើងឈប់ពាក់កណ្តាលទីនឹងហោសអ៊ី?

ខៈ នឹងហើយនឹងបើយើងមិនឈប់គាត់វៃនឹង

កៈ ចុះបើសិនជាចង់អោយអ៊ីផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗនឹងតើអីចង់ផ្ដែផ្ដាំអីទៅគាត់ដែរអ៊ី?

ខៈ ចង់ផ្ដែផ្ដាំថាកុំអោយស្ដាយក្រោយដូចជាខ្ញុំអោយខំប្រឹងរក នឹងខំរៀនទៅអោយឆ្លាតអោយមាន
ប្រាជ្ញាតទៅមុខទៀតវាមិនសាបសូន្យទេនឹង

កៈ ចឹងហោសអ៊ី?

ខៈ អស់មួយដល់មួយអស់មួយដល់មួយចឹងដូចនិយាយចឹងណាស់

កៈ បាទមានអីផ្សេងទៀតទេអ៊ី?

ខៈ អត់មានផងនឹង

កៈ ចុះបើសិនជាចង់អោយពួកគាត់ជៀសវៀងវិញតើអ៊ីចង់អោយពួកគាត់ជៀសវៀងពីអីគេដែរអ៊ី?

ខៈ ជៀសវៀងដូចថានៅក្នុងអំពើល្អចឹងណាស់

កៈ ចុះបើអំពើអាក្រក់អីចឹងហាសអ៊ី?

ខៈ បើយើងជៀសវៀងវិញដូចថាពេលរៀននឹងយើងត្រូវតែទៀងត្រង់ហើយយើងត្រូវតែស្ដាប់ដំបូន្មាន
របស់ម៉ែឪចឹងទៅណាស់ ចឹងយើងកុំដើរផ្លូវទៀតអី ហើយនឹងជក់គ្រឿងញៀនអីនឹងនាំតែអំពុលទុកដល់
ម៉ែឪអីនឹងយើងអាចសងគុណពួកគាត់រួចហើយបើសិនជាយើងជៀសផ្លូវនឹងបានចឹងហាស

កៈ បាទអ៊ីចឹង?

ខៈ ជិតសងគុណម៉ែឪហើយនឹង បើយើងជៀសមិនបានទេមានន័យថាយើងនាំទុកអោយម៉ែឪហើយនឹង
វេទនាក្រៀមក្រំខ្លោចផ្សារដោយសារតែរឿងនឹងទៀតនឹង

កៈ នឹងជាអ្វីដែរអ៊ីចង់អោយពួកគាត់ជៀសវៀងណាអ៊ី?

ខៈ នឹងហើយមានចឹង

កៈ ចឹងមានអីដែរអ៊ីចង់ផ្ដែផ្ដាំទៅពួកគាត់នឹងអីផ្សេងទៀតទេអ៊ី?

ខៈ បើផ្ដែផ្ដាំនឹងសូមអោយដើរផ្លូវល្អស្ដាប់ដំបូន្មានម៉ែឪទៅអីចឹងណាស់

កៈ បាទអីចឹងអត់មានអីទៀតទេណាអ៊ី?

ខៈ អត់មានអីទេនឹង

ក៖  ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនអ៊ីដែរបានអោយខ្ញុំបានសំភាសន៍ពីប្រវត្តិរបស់អ៊ី ហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលានឹងដើម្បីតំកល់ទុកអោយអ៊ីពេលក្រោយចឹងណាស់អ៊ីបាទអរគុណច្រើនអ៊ី៕៕៕